អេភេសូរ១:១៣-១៦

មកទល់ពេលនេះ យើងនៅធ្វើការសិក្សាបន្តពីប្រធានបទមួយស្តីពីឫសគល់នៃក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ដើម្បីបង្កើតក្រុមជំនុំអោយមានឡើងលើសកលលោកយើងនេះ ព្រះជាម្ចាស់បានរៀបចំផែនការរបស់ទ្រង់យ៉ាងជាក់លាក់តាំងពីមុនកំណើតលោកីយ៍មកម្ល៉េះ។ នៅក្នុងផែនការនោះ ព្រះវរបិតាទ្រង់ជាអ្នកធ្វើគម្រោងនិងគម្រូសម្រាប់អោយមានក្រុមជំនុំឡើង។ ព្រះរាជបុត្រាមាននាទីលោះក្រុមជំនុំរបស់ទ្រង់ចេញពីអំពើបាប។ ព្រះអង្គប្រើព្រះលោហិតរបស់ទ្រង់ជាថ្លៃលោះ។ មូលហេតុចម្បងបង្អស់ដែលនាំអោយព្រះជាម្ចាស់បង្កើតក្រុមជំនុំ គឺព្រះអង្គមានវត្ថុបំណងតែម្យ៉ាងគត់។ ឯវត្ថុបំណងនោះគឺ ក្រុមជំនុំត្រូវរស់នៅក្នុងជីវិតបរិសុទ្ធសម្រាប់ថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ពេលនេះ យើងនឹងពិចារណាពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ សម្រាប់ក្រុមជំនុំរបស់ព្រះអង្គ។ មុននឹងពិភាក្សាដំណើរនេះ សាវ័កប៉ុលរំឭកដល់យើងថា វត្ថុបំណងធំបង្អស់ដែលព្រះជាម្ចាស់បង្កើតក្រុមជំនុំ គឺសម្រាប់ជាទីសរសើរសិរីល្អដល់ទ្រង់។ តើព្រះវិញ្ញាណបរិសុទ្ធមានតួនាទីអ្វីសម្រាប់ក្រុមជំនុំរបស់ទង់?

## ព្រះវិញ្ញាណនៃព្រះ ថែរក្សាក្រុមជំនុំ

ក្រុមជំនុំរបស់ព្រះអង្គ មានជារូបរាងអស់រយៈពេលជាងពីរពាន់ឆ្នាំកន្លងមកហើយ។ បើតាមស្ថានភាពរបស់ក្រុមជំនុំដែលមានលក្ខណៈម្តងលិច ម្តងអណ្តែត ម្ល៉េះសមក្រុមជំនុំរលាយរលត់បាត់ពីផែនដីទៅហើយ បើព្រះវិញ្ញាណបរិសុទ្ធព្រះអង្គមិនបានថែទាំពួកអ្នកជឿទេ។ ដូច្នេះ តើព្រះវិញ្ញាណបរិសុទ្ធមានតួនាទីអ្វីខ្លះសម្រាប់ក្រុមជំនុំរបស់ទ្រង់? ព្រះវិញ្ញាណបរិសុទ្ធមានតួនាទីបីយ៉ាងសម្រាប់ក្រុមជំនុំ ដែលព្រះវរបិតានិងព្រះរាជបុត្រាបង្កើតមកអោយចេញជារូបរាង។ តួនាទីទាំងបីយ៉ាងនោះគឺ ទីមួយទ្រង់បង្កើតមនុស្សមានបាបអោយកើតជាថ្មី។ ទីពីរ ទ្រង់ឃុំគ្រងអ្នកដែលជឿដល់ព្រះអង្គ និងទីបី ព្រះអង្គបញ្ជាក់ពីធាតុពិតនៃចេស្តារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់ពួកអ្នកជឿ។ ឥឡូវ សូមយើងពិចារណាតួនាទីទីមួយ ព្រះវិញ្ញាណបរិសុទ្ធបង្កើតមនុស្សមានបាបអោយកើតជាថ្មីក្នុងព្រះគ្រីស្ទយេស៊ូវ។

**ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា (អេភេសូរ១:១៣)។**

ខ្ញុំផ្ទាល់ជឿថា ខគម្ពីរខាងលើនាំមកនូវសេចក្តីស្កប់ចិត្តយ៉ាងសែនមនោរម្យដល់យើងគ្រប់គ្នា។ ខនេះសម្តែងពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងការបង្កើតអោយ

មានក្រុមជំនុំរបស់ព្រះអង្គ។ តួនាទីទីមួយ ព្រះវិញ្ញាណបរិសុទ្ធបង្កើតជនមានបាបម្នាក់ អោយបានកើតជាថ្មីក្នុងអង្គព្រះយេស៊ូវគ្រីស្ទ។ ថ្វីដ្បិតក្នុងខនេះមិនបានសម្តែងអោយចំថា ព្រះវិញ្ញាណបរិសុទ្ធមានតួនាទីបង្កើតយើងជាថ្មីក៏ដោយ យើងឃើញកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធកំពុងទទួលនេះ ជាកិច្ចការដែលព្រះជាម្ចាស់កំពុងប្រគល់ក្រុមជំនុំរបស់ព្រះអង្គ អោយទៅព្រះវិញ្ញាណបរិសុទ្ធគង់ប្រថាប់ក្នុងក្រុមជំនុំ។ កិច្ចការរបស់ព្រះវរបិតា គឺទ្រង់រៀបគម្រោងការណ៍សម្រាប់ក្រុមជំនុំ។ កិច្ចការរបស់ព្រះរាជបុត្រា គឺទ្រង់លោះក្រុមជំនុំដោយប្រើព្រះលោហិតរបស់ទ្រង់ជាថ្លៃលោះ។ រីឯកិច្ចការព្រះវិញ្ញាណបរិសុទ្ធវិញ គឺថែរក្សាក្រុមជំនុំ។ ការថែរក្សាក្រុមជំនុំ គឺជាភារៈរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បន្តធ្វើការក្នុងចិត្តអ្នកជឿម្នាក់ៗ។

កិច្ចការដំបូងបង្អស់របស់ព្រះវិញ្ញាណបរិសុទ្ធ គឺព្រះអង្គបំផ្លាស់បំប្រែមនុស្សមានបាបម្នាក់អោយក្លាយទៅជាមនុស្សថ្មី។ នៅក្នុងការបង្កើតមនុស្សមានបាបអោយទៅជាអ្នកកើតជាថ្មី ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គពន្យល់ដល់មនុស្សមានបាបម្នាក់ ពេលគេឮព្រះបន្ទូល គេយល់ រួចហើយយល់ព្រមទទួលព្រះយេស៊ូវគ្រីស្ទធ្វើជាអង្គសង្គ្រោះ។ ក្នុងពេលដដែលនោះ ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គ បំផ្លាស់បុគ្គលរូបនោះ អោយក្លាយទៅជាកូនរបស់ព្រះ។ ដើម្បីអោយក្លាយទៅជាកូនរបស់ព្រះ ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានបន្ទូលថា "...ត្រូវតែកើតជាថ្មី" (យ៉ូហាន៣:៧)។ ឯគម្ពីរយ៉ូហាន១:១២ចែងទៀតថា "ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ"។ ដើម្បីអោយបានកើតជាថ្មី យើងគ្រាន់តែ

ជឿដល់ព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។

"ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត"។ ការឮព្រះបន្ទូល មិនមែនមានន័យថា គ្រាន់តែឮគេនិយាយពីព្រះអម្ចាស់យេស៊ូវតែប៉ុណ្ណោះទេ។ យើងត្រូវឮហើយយល់ថែមទៀត។ សាវ័កប៉ុលបញ្ជាក់ក្នុងគម្ពីរ១កូរិនថូស១:២៣-២៤ថា "...យើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវឆ្កាងវិញ ជាហេតុនាំឱ្យរវាតចិត្តដល់សាសន៍យូដា នឹងជាសេចក្ដីល្ងង់ល្ងើដល់សាសន៍ក្រេក តែព្រះគ្រីស្ទ ទ្រង់ជាព្រះចេស្ដា ហើយជាប្រាជ្ញារបស់ព្រះវិញដល់អស់អ្នកដែលទ្រង់ហៅ ទាំងសាសន៍យូដា ហើយនឹងសាសន៍ក្រេកផង"។ តើជនណាមួយដែលរាប់ថា ជាជនដែលព្រះជាម្ចាស់ត្រាស់ហៅ? ជនដែលទទួលការត្រាស់ហៅរបស់ព្រះជាម្ចាស់ គឺអ្នកដែលឮព្រះបន្ទូលរបស់ព្រះអង្គហើយយល់ស្របតាមព្រះបន្ទូលព្រះអង្គដែលត្រចៀកខ្លួនបានឮ។ ព្រះជាម្ចាស់ត្រាស់ហៅអស់អ្នកណាដែលយល់ដល់ព្រះបន្ទូលរបស់ព្រះអង្គ។ អ្នកដែលយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឮព្រះបន្ទូលរួចហើយ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គធ្វើអោយព្រះបន្ទូលមានន័យសម្រាប់ជីវិតរបស់ខ្លួន។ គម្ពីររ៉ូម១០:១៧ចែងថា ជំនឿកើតមកពីការឮ ឯការឮនោះទៀតសោត គឺឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកដែលទទួលការត្រាស់ហៅពីព្រះជាម្ចាស់ ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ យល់ព្រមទទួលព្រះបន្ទូលដាក់ក្នុងចិត្តដោយអំណរ។ ក្នុងខណៈដែលជននោះ ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើមានអ្វីកើតឡើងដល់ជីវិតរបស់ខ្លួន? គម្ពីរ១ពេត្រុស១:២៣ឆ្លើយថា "ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយ

វិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់"។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ កំពុងធ្វើដំណើរចេញទៅលឿនស្លេវ។ ខណៈនេះ លោកអ្នកកំពុងតែស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលកំពុងជ្រាបចូលក្នុងចិត្តលោកអ្នកហើយ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែងថា ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះអម្ចាស់យេស៊ូវគ្រិស្តសុគតជំនួសអំពើបាបរបស់លោកអ្នក។ បើលោកអ្នកព្រមជឿដល់ព្រះបន្ទូលនេះ លោកអ្នកបានទទួលសេចក្តីសង្គ្រោះជាពិត។ នៅពេលដែលឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកខ្លះស្តាប់ទៅហាក់ដូចជាគ្មានន័យ។ អ្នកខ្លះទៀតស្តាប់ទៅមានរសផ្អែមនៅក្នុងវិញ្ញាណរបស់ខ្លួន។ អ្នកដែលស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ រួចហើយព្រះបន្ទូលនោះធ្វើអោយចិត្តគេមានសេចក្តីល្វែល្វើយ មកពីចិត្តរបស់អ្នកនោះ យល់ស្របជាមួយនឹងការពន្យល់របស់ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ក្នុងវិនាទីដែលបុគ្គលម្នាក់ទទួលជឿព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងវិនាទីនោះហើយ ដែលបុគ្គលនោះបានកើតជាថ្មី។ ជំនឿ ត្រូវកើតឡើងព្រមគ្នាក្នុងពេលដែលបុគ្គលម្នាក់ឮ ហើយយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជំនឿមិនអាចកើតមុនពេលឮព្រះបន្ទូលទេ។ "ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ..."។ ការកើតជាថ្មីត្រូវចាប់បដិសន្ធិក្នុងពេល ដែលបុគ្គលម្នាក់ឮហើយយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើព្រះបន្ទូលនៃសេចក្តីពិតគឺជាអ្វី? ព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អដែលនាំមកនូវសេចក្តីសង្គ្រោះ និងការរំដោះអោយមានសេរីភាព។ លុះលោកអ្នកឮព្រះបន្ទូលនៃសេចក្តីពិត លោកអ្នកដាក់ជំនឿរបស់លោកអ្នកទៅលើអង្គព្រះគ្រិស្តយេស៊ូវ។

"ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា"។ នៅក្នុង១១៣ យើងឃើញមានពាក្យថា "បានឮព្រះបន្ទូល បានជឿហើយ នោះទ្រង់ក៏ដៅចំណាំ"។ នៅក្នុងភាសាដើម គឺភាសាក្រេក កិរិយាស័ព្ទឮ និងកិរិយាស័ព្ទជឿ ប្រើក្នុងវេយ្យាករណ៍ជាបច្ចុប្បន្នកាល។ ពាក្យ "បាន" និយាយសំដៅពេលដែលកន្លងហួសទៅហើយ។ នៅក្នុងភាសាក្រេកមិនមានប្រើពាក្យ "បាន"នេះទេ។ បើតាមអត្ថបទដើម១១៣គួរបកប្រែថា "ឯអ្នករាល់គ្នាឮព្រះបន្ទូលនៃសេចក្តីពិត អមដោយចិត្តជឿ ទ្រង់ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់សន្យា"។ កិរិយាស័ព្ទទាំងបីនេះ គឺឮ ជឿ ហើយនិងដៅចំណាំ ត្រូវកើតឡើងព្រមគ្នាក្នុងមួយពេល។ កាលណាបុគ្គលម្នាក់ឮព្រះបន្ទូល ជឿព្រះបន្ទូល អំឡុងពេលនោះ ព្រះវិញ្ញាណបរិសុទ្ធដៅចំណាំជននោះថា ជាកូនរបស់ព្រះជាម្ចាស់។ ការដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធនោះហើយ។ លោកអ្នកទទួលការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ក្នុងវិនាទីដែលលោកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ។ ក្នុងពេលដដែលនោះ ព្រះវិញ្ញាណរបស់ព្រះអង្គ ដៅចំណាំលោកអ្នកថា ជាកូនរបស់ព្រះអង្គ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺទ្រង់ដុសត្រចៀកអោយយល់ដាំឮជជំនឿ និងដៅចំណាំទុកជាកូនរបស់ទ្រង់។

ទាក់ទងនឹងការដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ មានគេលើកជាសំណួររហូតដល់មានការប្រកែកប្រណាំងគ្នាថា តើអង្គណាបំពេញតួនាទីជាអ្នកដៅចំណាំអ្នកជឿម្នាក់ថា ជាកូនរបស់ព្រះអង្គ? តើព្រះវរបិតា ឬព្រះរាជបុត្រា ឬព្រះវិញ្ញាណបរិសុទ្ធ

បើលោកអ្នកមានសំណួរបែបនេះ លោកអ្នកជាជនដែលយកសក់មួយសរសៃច្រៀកចែកជាមួយពាន់ចំរៀកហើយ។ ក្នុងបញ្ហានេះ យើងមិនចាំបាច់សួរនាំអ្វីអោយកើតជាជម្លោះទេ។ សំណួរនេះឥតនាំមកនូវអត្ថប្រយោជន៍អ្វីសម្រាប់អ្នកជឿឡើយ។ បើតាមខ្ញុំយល់ ខគម្ពីរខាងលើថែងយ៉ាងច្បាស់ថា ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ជាអ្នកបំពេញតួនាទីដៅចំណាំដល់ពួកអ្នកជឿព្រះយេស៊ូវគ្រីស្ទ។ ព្រះវរបិតាបញ្ជូនព្រះរាជបុត្រាអោយមកសុគតនៅលើឈើឆ្កាង។ ព្រះរាជបុត្រាយាងមកទទួលសុគត ដោយព្រះហឫទ័យស្មោះស្ម័គ្រ។ ដូច្នេះ ទាំងព្រះវរបិតា ទាំងព្រះរាជបុត្រា ជាអង្គដែលបរិច្ចាគអង្គទ្រង់។ ព្រះវរបិតា និងព្រះរាជបុត្រាបញ្ជូនព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គអោយមកបំពេញតួនាទីសម្រាប់ក្រុមជំនុំរបស់ព្រះអង្គ។ ឯតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គគឺ ទីមួយ បង្កើតមនុស្សអោយកើតជាថ្មីក្នុងព្រះគ្រីស្ទ ហើយក្នុងពេលដដែលនោះព្រះវិញ្ញាណបរិសុទ្ធព្រះអង្គដៅចំណាំអ្នកជឿម្នាក់ៗថា ជាកូនរបស់ព្រះអង្គ។ បើតាមខគម្ពីរនេះ អង្គដែលទទួលធ្វើការដៅចំណាំដល់ពួកអ្នកជឿ គឺព្រះវិញ្ញាណបរិសុទ្ធ។

ព្រះវិញ្ញាណបរិសុទ្ធដៅចំណាំអ្នកជឿម្នាក់ៗ ដោយមានមូលហេតុពីរយ៉ាង។ ម្យ៉ាង ព្រះអង្គបណ្ដុះលក្ខណៈជាព្រះនៅក្នុងចិត្តរបស់ពួកអ្នកជឿ ដើម្បីអោយគេអាចអនុវត្តធាតុពិតនៃចេស្ដារបស់ព្រះនៅក្នុងជីវិតរបស់ខ្លួន។ ធម្មតាគេប្រើត្រា ដើម្បីបោះលើឯកសារណាមួយបញ្ជាក់ថា អាជ្ញាធរតំបន់ណាមួយយល់ព្រមដល់សេចក្ដីដែលបានរៀបរាប់នៅក្នុងឯកសារនោះ។ ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គ ប្រើត្រាជាព្រះអង្គទ្រង់ផ្ទាល់ ដើម្បីបញ្ជាក់ថា អ្នកជឿរូបនោះ ពិតជាកូនរបស់ព្រះជាម្ចាស់មែន។ យ៉ូហាន

៣:៣៣ចែងថា "អ្នកណាដែលទទួលសេចក្តីបន្ទាល់របស់ទ្រង់ នោះបានបោះត្រា យល់ព្រមថា ព្រះទ្រង់ពិតត្រង់មែន"។ ខគម្ពីរនេះចែងថា ព្រះជាម្ចាស់បានយល់ព្រមអោយព្រះវិញ្ញាណបោះត្រារបស់ព្រះអង្គ នៅលើចិត្តរបស់អស់អ្នកណាដែលជឿដល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ។ មូលហេតុទីពីរ ដែលព្រះវិញ្ញាណបោះត្រានៅលើចិត្តរបស់អ្នកជឿ គឺព្រះអង្គបញ្ជាក់ប្រាប់អ្នកជឿរូបនោះថា គេជាកម្មសិទ្ធិពេញសិទ្ធិរបស់ព្រះអង្គ។ គម្ពីរ២ធីម៉ូថេ២:១៩ បញ្ជាក់ថា "ប៉ុន្តែ ឯឫសមាំមួនរបស់ព្រះ នោះធន់នៅវិញដោយបានបោះត្រាថា ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែលជារបស់ផងទ្រង់ ហើយថា ចូរឱ្យអស់អ្នក ដែលចេញព្រះនាមព្រះអម្ចាស់ ថយចេញពីសេចក្តីទុច្ចរិតទៅ"។ ត្រង់នេះ សូមលោកអ្នកយល់អោយបានច្បាស់ថា ការធានាសុវត្ថិភាពថា លោកអ្នកពិតជាកូនរបស់ព្រះអង្គ មិនមែនមានន័យថា លោកអ្នកអាចប្រព្រឹត្តអំពើបាបបន្ថែមទៀតបានទេ។ ល្គឹកណាលោកអ្នកដូរត្រកូលរបស់លោកអ្នក ជាប់នឹងត្រកូលរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទហើយ លោកអ្នកពិតជាយល់ព្រមឈប់ប្រព្រឹត្តអំពើបាបតទៅទៀត។ បើលោកអ្នកបានទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះរួចហើយ តែគ្មានភស្តុតាងណាបញ្ជាក់ថា លោកអ្នករស់នៅក្នុងសេចក្តីសុចរិតដូចព្រះអង្គទេ លោកអ្នកមិនទាន់បានកើតជាថ្មីនៅឡើយ។ ឯព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ក៏មិនទាន់បានដៅចំណាំលោកអ្នកថា ជាកូនរបស់ព្រះអង្គដែរ។

ម្យ៉ាងទៀត ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គដៅចំណាំដើម្បីធានាថា ដល់ថ្ងៃព្រះជាម្ចាស់លើកយកពួកជំនុំរបស់ព្រះអង្គទៅនៅជាមួយទ្រង់ លោកអ្នកក៏បានទៅ

ជាមួយនឹងគេដែរ។ ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គដៅចំណាំយើង ទុកសម្រាប់ថ្ងៃប្រោសលោះ។ នៅថ្ងៃព្រះអម្ចាស់យេស៊ូវយាងមកលើកក្រុមជំនុំរបស់ព្រះអង្គ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ បានប្រគល់យើងទៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះគ្រីស្ទយេស៊ូវហើយ។ ធម្មតា កាលណាយើងផ្ញើសំបុត្រទៅកាន់នរណាម្នាក់ យើងសរសេរសំបុត្រ រួចហើយ ច្រកក្នុងស្រោម បិទស្រោមសំបុត្រនោះអោយជិត។ នៅក្នុងប្រទេសសេរី អ្នករត់សំបុត្រ គ្មានសិទ្ធិបើកសំបុត្រអ្នកដទៃទេ។ ភារៈរបស់អ្នករត់សំបុត្រ ត្រូវយកសំបុត្រទៅប្រគល់ដល់អ្នកដែលត្រូវទទួល។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបោះត្រាលើចិត្តរបស់ពួកអ្នកជឿ ដើម្បីប្រគល់ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅថ្ងៃប្រោសលោះ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ទីមួយ ព្រះអង្គបង្កើតមនុស្សជាថ្មី ទីពីរ ព្រះអង្គដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ។

ឥឡូវនេះ សូមយើងពិចារណាពីកិច្ចការទីបីដែលព្រះវិញ្ញាណបរិសុទ្ធក្នុងការថែរក្សាក្រុមជំនុំរបស់ព្រះអង្គ។

**ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឱ្យយើងនោះ សំរាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់ (អេភេសូរ១:១៤)។**

ព្រះវិញ្ញាណបំពេញតួនាទីជាអង្គបញ្ចាំចិត្ត។ នៅក្នុងសម័យបច្ចុប្បន្នគេហៅវត្ថុបញ្ចាំចិត្តថា ជាប្រាក់កក់វិញ។ ព្រះវិញ្ញាណបរិសុទ្ធជាប្រាក់កក់សម្រាប់យើង។ ដើម្បីទិញរបស់អ្វីមួយ បើយើងមិនទាន់មានប្រាក់គ្រប់ចំនួន យើងគ្រាន់តែកក់គេទុកជាមុនសិន។ ប្រាក់កក់មានន័យថា យើងនឹងយកប្រាក់មកបង់បង្គ្រប់តម្លៃរបស់នោះក្នុងពេលកំណត់ណាមួយខាងមុខ។ ព្រះវិញ្ញាណបរិសុទ្ធកក់ព្រះវិញ្ញាណទ្រង់នៅក្នុងចិត្តយើង ដើម្បីអោយយើងអាចទទួលកេរអាករ ដែលព្រះជាម្ចាស់បម្រុងទុកអោយយើង។ ឯកេរអាករនោះទៀតសោត គឺជាព្រះពរខាងព្រលឹងវិញ្ញាណ។ យើងត្រូវទទួលកេរអាករដែរ។ ឯសិទ្ធិដែលយើងត្រូវទទួលកេរអាករ គឺយើងត្រូវមានព្រះវិញ្ញាណបរិសុទ្ធជាទីបញ្ចាំចិត្តយើងជាមុន។

ហេតុការណ៍ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើទាំងបីយ៉ាងនេះ គឺសម្រាប់អោយក្រុមជំនុំមានលទ្ធភាពអាចថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ឃ្លានេះយើងឃើញសាវ័កប៉ុលបញ្ជាក់ថា "...សំរាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់"។ សាវ័កប៉ុលបានសង្កត់ពាក្យនេះចំនួនបីដង គឺម្ដងបន្ទាប់ពីលោកពន្យល់ពីតួនាទីរបស់ព្រះវរបិតាក្នុងការៀបចំបង្កើតក្រុមជំនុំរបស់ទ្រង់។ ព្រះវរបិតារៀបចំគម្រោងបែបនោះ ដើម្បីអោយក្រុមជំនុំចេះសរសើរសិរីល្អនៃទ្រង់ (ខ៦)។ បន្ទាប់មកទៀត លោកបញ្ជាក់ម្ដងទៀតនៅក្នុងខ១២ថា "សំរាប់នឹងសរសើរដល់សិរីល្អទ្រង់" បន្ទាប់ពីលោកពន្យល់ពីតួនាទីរបស់ព្រះរាជបុត្រា ដែលទ្រង់បានបំពេញសម្រាប់ធ្វើអោយមានក្រុមជំនុំ។ រីឯបទសរសើរទីបី លោកសរសេរបន្ទាប់ពីលោកពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គ បង្កើតមនុស្សអោយកើត

ជាថ្មី រួចហើយបោះត្រាដៅចំណាំ ព្រមទាំងធ្វើអោយអ្នកជឿដឹងច្បាស់នៅក្នុងចិត្តថា គេជាកូនរបស់ព្រះអង្គ។ ការទាំងអម្បាលមាណនេះ ព្រះវិញ្ញាណបរិសុទ្ធធ្វើឡើងដល់ក្រុមជំនុំសម្រាប់ជាសេចក្តីសរសើរដល់សិរីល្អនៃព្រះជាម្ចាស់។

បន្ទាប់ពីសាវ័កប៉ុលពន្យល់ពីតួនាទីរបស់ព្រះត្រៃសរណគមន៍ ក្នុងការបង្កើតក្រុមជំនុំ លោកបានបរិយាយពីសេចក្តីអធិស្ឋានសម្រាប់ក្រុមជំនុំនៅទីក្រុងអេភេសូរ។

## សាវ័កប៉ុលអធិស្ឋានសូមអោយក្រុមជំនុំនៅទីក្រុងអេភេសូរ មានចេស្តានិងការចម្រើនខាងជំនឿ

**១៥ដោយហេតុនោះ កាលខ្ញុំឮនិយាយពីសេចក្តីជំនឿដែលអ្នករាល់គ្នាមាន ដល់ព្រះអម្ចាស់យេស៊ូវ ហើយនឹងពីសេចក្តីស្រឡាញ់ដែលមានដល់ពួកបរិសុទ្ធទាំងអស់គ្នា ១៦នោះខ្ញុំមិនដែលលែងអរព្រះគុណ ដោយព្រោះអ្នករាល់គ្នាឡើយ គឺខ្ញុំតែងដំណាលពីអ្នករាល់គ្នា ក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំវិញ (អេភេសូរ១:១៥-១៦)។**

លក្ខណៈសម្បត្តិដោយឡែករបស់ក្រុមជំនុំនៅទីក្រុងអេភេសូរ អាចសម្គាល់បានជំនឿនិងសេចក្តីស្រឡាញ់។ ពួកជំនុំនៅទីក្រុងអេភេសូរស្រឡាញ់គ្នាយ៉ាងប្តូរផ្តាច់។ មូលហេតុដែលពួកអ្នកជឿនៅទីនោះស្រឡាញ់គ្នាយ៉ាងខ្លាំង ពីព្រោះគេមានជំនឿលើ

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ក្រុមជំនុំអេភេសូរជាគម្រូនៃក្រុមជំនុំពិតប្រាកដ។ ក្រុមជំនុំនោះមានសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់ជាអត្តសញ្ញាណសម្រាប់ក្រុម។ បើតាមការវិនិច្ឆ័យក្នុងគម្ពីរវិវរណៈ ក្រុមជំនុំនៅទីក្រុងអេភេសូរ ជាក្រុមជំនុំល្អជាងគេបំផុតក្នុងសម័យដើម។ ដោយឃើញអ្នកជឿនៅទីនោះ មានជំនឿយ៉ាងមុតមាំលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រមទាំងមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក សាវ័កប៉ុលថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់។

សេចក្ដីខាងលើ ជាសេចក្ដីបង្រៀនសម្រាប់យើងរាល់គ្នាជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលរស់នៅគ្រប់កាលសម័យ។ យើងជារាស្ត្ររបស់ព្រះជាម្ចាស់ ជួនកាលយើងជួបប្រទះនឹងទុក្ខលំបាកមានជម្ងឺឈឺថ្កាត់ ពិបាកចិត្ត ឬមានគ្រោះកាចណាមួយកើតឡើងដល់យើង ទើបយើងអធិស្ឋានស្វែងរកព្រះហឫទ័យបំណងព្រះអង្គ។ ខ្ញុំធ្លាប់ទទួលពាក្យសំណូមពីពួកជំនុំខ្លះអោយជួយអធិស្ឋានអោយគេផង ដ្បិតក្រុមជំនុំរបស់គេមានទុក្ខលំបាកបង្កឡើងដោយខ្វះសេចក្ដីស្រឡាញ់ ការនិយាយដើមគ្នា និងមិនចូលចិត្តរៀនព្រះបន្ទូលព្រះ។ ខ្ញុំអធិស្ឋានដល់ពួកជំនុំនោះ ពីព្រោះខ្ញុំមានចិត្តស្រឡាញ់អ្នកជឿទាំងអម្បាលមាណ ដែលរស់នៅក្នុងភូមិស្រុកមួយនោះ។ យើងចូលចិត្តអធិស្ឋានពេលណាដែលយើងមានរឿងរ៉ាវ។ ចំណែកសាវ័កប៉ុលវិញ លោកអធិស្ឋានដល់ក្រុមជំនុំនៅទីក្រុងអេភេសូរ ពេលដែលលោកឃើញក្រុមជំនុំនៅទីនោះមានគម្រូល្អជាប្រក្រតី។ ខ្ញុំសូមសួរដល់លោកអ្នកបងប្អូនថា បើលោកអ្នកបានឮដំណឹងពីកូនរបស់ព្រះជាម្ចាស់រូបណាមួយបានធ្វើល្អ តើលោកអ្នកថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ ដោយព្រះ

ជាម្ចាស់បានប្រើលោកដូច្នោះដែរឬទេ? ពេលដែលលោកអ្នកឮថា ក្រុមជំនុំណាមួយបាន រីកចម្រើន តើលោកអ្នកលុតជង្គង់ថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់ដែរឬទេ? យើងជាមនុស្សជាតិ មិនសូវមានចិត្តរីករាយជាមួយនឹងអ្នកណាមានការរីកចម្រើនទេ។ ពេលយើងអធិស្ឋាន យើងតែងតែចូលមកចំពោះព្រះអង្គ មានទាំងបញ្ជីកាន់នឹងដៃផង ថា "ឱព្រះអង្គអើយ ទូលបង្គំចង់បាននេះ ចង់បាននោះ ចង់បានរបស់ផ្សេងទៀត ចង់បានច្រើនជាងរបស់ដែលខ្ញុំមានសព្វថ្ងៃ"។ ខ្លះទៀត មិនគ្រាន់តែអធិស្ឋានទូលសូមការចង់បានពីព្រះអង្គ មិនតែប៉ុណ្ណោះទេ គេសម្លុតព្រះអង្គថា "ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ អោយរបស់ចង់បានមកទូលបង្គំពេលឥឡូវនេះ!" សូមចាំថា ព្រះជាម្ចាស់មិនមែនជាអាគាំងចៅតាសម្រាប់យើងទេ។ ពេលចូលទៅព្រះអង្គ សូមចេះថ្លែងពាក្យអំណរគុណដល់ព្រះអង្គផង។

ពេលសាវ័កប៉ុលឮដំណឹងរីករាយពីក្រុមជំនុំនៅទីក្រុងអេភេសូរ លោកមានប្រសាសន៍ថា "នោះខ្ញុំមិនដែលលែងអរព្រះគុណដោយព្រោះអ្នករាល់គ្នាឡើយ"។ សាវ័កប៉ុលចូលចិត្តអធិស្ឋានខ្លាំងណាស់។ មិនតែប៉ុណ្ណោះ លោកក៏ជាបេសកជនយ៉ាងចំណានមួយរូប។ លើសពីនោះទៅទៀត សាវ័កប៉ុលជាគ្រូអធិប្បាយយ៉ាងចំណានក្នុងចំណោមគ្រូអធិប្បាយដប់រូបចំណានៗជាងគេបង្អស់។ លើកលែងតែព្រះអម្ចាស់យេស៊ូវ ឥតមានជនណាមួយពូកែអធិប្បាយដូចសាវ័កប៉ុលទេ។ មិនតែប៉ុណ្ណោះសោត សាវ័កប៉ុលស្រឡាញ់ពួកជំនុំនៅទីក្រុងអេភេសូរយ៉ាងខ្លាំង។ នៅថ្ងៃដែលលោកលាពួកជំនុំនៅទីនោះ បណ្ឌិតលូកាវៀបរាប់ថា សាវ័កប៉ុលយំជាមួយនឹងពួកចាស់ទុំ។

យើងអាចវិនិច្ឆ័យក្រុមជំនុំណាមួយ ថាជាក្រុមជំនុំមានវិញ្ញាណខ្ពង់ខ្ពស់ ដោយសារកម្រិតដែលគេស្រឡាញ់ដល់គ្រូគង្វាល ព្រមទាំងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈគ្រូគង្វាលរបស់ខ្លួន។ ឯបុគ្គលដែលយើងយល់ថា ជាអ្នកស្រឡាញ់ដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនជាបុគ្គលម្នាក់ដែលទៅណាមកណាស្ពាយគម្ពីរទៅជាមួយខ្លួនរហូតទេ ម្យ៉ាងទៀត អ្នកស្រឡាញ់ព្រះជាម្ចាស់មិនមែនជាជន ដែលពូកែនិយាយភាសាព្រលឹងវិញ្ញាណយ៉ាងផ្អែមពីរោះដែរ។ ខ្ញុំធ្លាប់ចាញ់បោកគ្រីស្ទានគ្មានព្រះគុណប្រភេទនេះ ច្រើនលើកច្រើនសារហើយ។ ជនដែលស្រឡាញ់ព្រះជាម្ចាស់ ជាជនដែលអនុវត្តព្រះបន្ទូលរបស់ព្រះអង្គវិញ។ ពួកជំនុំនៅទីក្រុងអេភេសូរស្រឡាញ់សាវ័កប៉ុល ថែមទាំងស្តាប់ព្រះបន្ទូលដែលសាវ័កប៉ុលអធិប្បាយបង្រៀនដល់គេផង។

សាវ័កប៉ុលជាបុគ្គលដែលចូលចិត្តអធិស្ឋានយ៉ាងខ្លាំង។ នៅក្នុងព្រះគម្ពីរបុគ្គលដែលចូលចិត្តអធិស្ឋានមាន លោកម៉ូសេ ស្តេចដាវីឌ ហោរាអេលីយ៉ា និងហោរាដានីយ៉ែល។ ចំណែកព្រះអម្ចាស់យេស៊ូវគ្រីស្ទត្រូវទទួលចំណាត់ថ្នាក់ទីមួយក្នុងការចូលចិត្តអធិស្ឋាន។ ដោយសារព្រះអង្គចូលចិត្តអធិស្ឋាន បានជាគម្ពីរលូកា១១:១ចែងថា សាវ័ករបស់ទ្រង់ សូមអោយព្រះអង្គបង្ហាត់បង្រៀនពួកលោកអោយចេះអធិស្ឋានដូចទ្រង់ដែរ។

នៅពេលដែលសាវ័កប៉ុលអធិស្ឋាន តើលោកអធិស្ឋានពីអ្វីខ្លះ? នៅក្នុងសំបុត្រដែលលោកសរសេរទៅកាន់ពួកជំនុំទីក្រុងអេភេសូរ លោកបញ្ជាក់ពីសំណូមសេចក្តីអធិស្ឋានពីរយ៉ាង។ សំណូមសេចក្តីអធិស្ឋានទាំងពីរយ៉ាងនោះ ជាសេចក្តីអធិស្ឋានក្នុង

ចំណោមសេចក្តីអធិស្ឋានជាច្រើនទៀត ដែលលោកធ្វើការអធិស្ឋានសម្រាប់ក្រុមជំនុំ។ សំណូមសេចក្តីអធិស្ឋានទីមួយ ដែលសាវ័កប៉ុលថ្វាយជាការសរសើរដល់ព្រះអង្គ គឺព្រះជាម្ចាស់បានរាប់កូនចៅអ៊ីស្រាអែល ជាចំណែកនៅក្នុងរូបកាយ គឺក្រុមជំនុំរបស់ព្រះអង្គដែរ។ ឯសំណូមសេចក្តីអធិស្ឋានមួយទៀត លោករៀបរាប់នៅចុងបញ្ចប់នៃគម្ពីរអេភេសូរជំពូក៣។ សំណូមនោះគឺ "ដើម្បីឱ្យទ្រង់បានប្រោសប្រទានឱ្យអ្នករាល់គ្នាបានព្រះចេស្តា ចំរើនកំឡាំងនៃមនុស្សខាងក្នុង ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ឱ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ ប្រយោជន៍ឱ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្តីស្រឡាញ់ ដើម្បីឱ្យអាចនឹងយល់ ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នា ពីទទឹង បណ្តោយ ជំរៅ នឹងកំពស់នៃសេចក្តីស្រឡាញ់នោះ ហើយឱ្យបានស្គាប់សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ឱ្យអ្នករាល់គ្នាបានពេញដល់គ្រប់ទាំងសេចក្តីពោរពេញរបស់ផងព្រះ" (អេភេសូរ៣:១៦-១៩)។ សេចក្តីអធិស្ឋានទាំងពីរយ៉ាងនោះ ជាការព្រួយបារម្ភរបស់សាវ័កប៉ុល ចំពោះពួកអ្នកជឿទូទៅ ដែលជាកូនរបស់ព្រះជាម្ចាស់។

"នោះខ្ញុំមិនដែលលែងអរព្រះគុណ ដោយព្រោះអ្នករាល់គ្នាឡើយ"។ សាវ័កប៉ុលថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់ ដោយព្រោះពួកជំនុំនៅទីក្រុងអេភេសូរជឿដល់ព្រះអង្គ ព្រមទាំងស្រឡាញ់ដល់គ្នាទៅវិញទៅមក។

"គឺខ្ញុំតែងដំណាលពីអ្នករាល់គ្នា ក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំវិញ"។ ត្រង់នេះ សាវ័កប៉ុលអធិស្ឋានដល់ពួកជំនុំនៅទីក្រុងអេភេសូរ ដោយរៀបរាប់ឈ្មោះគេរៀងរាល់

រូប។ ពេលលោកអ្នកអធិស្ឋានដល់ពួកជំនុំ សូមលោកអ្នករៀបរាប់ឈ្មោះរបស់អ្នកដែលលោកអ្នកចង់អធិស្ឋានទូលថ្វាយដល់ព្រះជាម្ចាស់ចំៗតែម្តង។

យើងស្លេះការសិក្សាគម្ពីរអេភេសូរត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"